ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ១៧/១១.០១.២០១០
សាលដីកា
១៩ ក្រ.III.ស /២២.១០.២០១៤

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៤ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីធ្វើការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ១៧ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១០ រវាង៖

ជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន ហៅ [redacted] ប៊ុនឈឿន ហៅ តុង ភេទប្រុស អាយុ៤៨ឆ្នាំ ជាតិខ្មែរ មុខរបរដូរទឹកអាគុយ កើតនៅ [redacted] ទីលំនៅមុនពេលចាប់ខ្លួន [redacted] ឪពុកឈ្មោះ [redacted] (ស) ម្តាយ ឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន០២នាក់ ទោសពីមុនគ្មាន។

មេធាវីការពារលោក [redacted] ប៊ុល។

<u>ជាប់ចោទពីបទ:</u> ប្លន់ ប្រព្រឹត្តនៅ ភូមិត្រពាំងពើក ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០០៧ តាមមាត្រា៦ នៃច្បាប់ស្តីពីស្ពានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

ជនរងគ្រោះឈ្មោះ [redacted] រតន: ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ បច្ចុប្បន្នរស់នៅ [redacted]

ជនរងគ្រោះឈ្មោះ [redacted] ចាន់ណារី ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ បច្ចុប្បន្នរស់នៅ [redacted] ៗ

## ដំណើររឿងមានដូចតទៅ៖

កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៧ វេលាម៉ោង២១ និង១០នាទី នៅភូមិត្រពាំងពើក ឃុំពើក ស្រុក អង្គស្នួល ខេត្តកណ្តាល មានករណីប្លន់ កើតឡើងប្រព្រឹត្តដោយឈ្មោះ [redacted] ប៊ុនធឿន និងមនុស្សពីរនាក់ ទៀតជិះម៉ូតូមួយគ្រឿងម៉ាកសេ១០០ កូរ៉េ ពណ៌កំបោរ និងមានអាវុធអាកា៤៧ កាត់ស្វាយ០១ដើម បានវាយ និងភ្ជង់ទៅលើឈ្មោះ [redacted] រតនៈ និង [redacted] ចាន់ណារី ប្លន់យកម៉ូតូ ម៉ាកសេ១២៥ សេរី ឆ្នាំ២០០៦ ពណ៌ខ្មៅ លេខតួ៧៣៥២ លេខម៉ាស៊ីន៧៣៥៣ ស្លាកលេខ១B ៩៤៤៤។ នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ត្រូវ សមត្ថកិច្ចរាជធានីភ្នំពេញ ចាប់ខ្លួន និងឃុំខ្លួន នៅពន្ធនាគារព្រៃស រហូតដល់ពេលបច្ចុប្បន្ន។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៣៩ «ឌ» ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១. ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន [redacted] តុង ភេទប្រុស អាយុ៤៨ឆ្នាំ ដាក់ពន្ធនាគារកំណត់៦ឆ្នាំ គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី២២ ខែមករា ឆ្នាំ២០០៩ ពីបទ ប្លន់ ប្រព្រឹត្តនៅ ភូមិត្រពាំងពើក ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៧ តាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២. សាលក្រមនេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ កំបាំងមុខជនរងគ្រោះ។ បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ប៊ុនឈឿន ជាជនជាប់ចោទ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៩«ឌ» ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សា បញ្ជាក់អង្គហេតុរឿងជូនអង្គសវនាការ

ជនជាប់ចោទឈ្មោះ [redacted] ប៊ុនឈឿន ឆ្លើយថា នៅថ្ងៃកើតហេតុនោះ ខ្លួននៅដេកចិញ្ចឹមជ្រូកនៅខេត្តព្រៃវែងឯណោះ មិនបានមកភ្នំពេញទេ,

ក្រោយក្រុមប្រឹក្សាសាកសួរបញ្ជាក់ ទើបជនជាប់ចោទឆ្លើយទទួលស្គាល់ថា នៅពេលនោះ ខ្លួនបានដឹកមនុស្ស២នាក់ ពីចោមចៅទៅផ្តល់ទទឹងស្រុកអង្គស្នួល។ លុះទៅដល់ទីនោះ(កន្លែងកើតហេតុ) នៅវេលាម៉ោង៦ល្ងាច ខ្លួនទៅទិញបារីនៅក្បែរនោះ មួយសន្ទុះ ក្រោយមក ខ្លួនឃើញហេតុការណ៍កើតឡើងនៅកន្លែងដែលពីរនាក់នោះដើរចូលទៅ។ ខ្លួនជាអ្នករត់ម៉ូតូឌុប ខ្លួនពុំដឹងថាពីរនាក់នោះមានកាំភ្លើងទេ បើដឹងខ្លួនមិនឌុបគេទេ។

ជនរងគ្រោះឈ្មោះ [redacted] រតនៈ ឆ្លើយថា នៅថ្ងៃកើតហេតុនោះ ខ្លួន និងគូដណ្តឹង បានជិះម៉ូតូទៅ

ញុំាំបង្អែមនៅឯស្ពានគុណាគ្រូ នៅវេលាម៉ោង១៧ និង៣០នាទី រួចត្រឡប់មកវិញដល់ ផ្លូវបត់ចូលភូមិត្រពាំងពើក គូដណ្តឹងខ្លួនក៏បត់ចូលភូមិ ស្រាប់តែក្រុមជនជាប់ចោទមានគ្នា៣នាក់ មកស្ទាក់ប្លន់យកម៉ូតូគូដណ្តឹងខ្លួនជិះទៅបាត់។ នៅពេលនោះជនជាប់ចោទរូបនេះហើយ ដែលជាអ្នកវាយខ្លួនបែកក្បាលហូរឈាម ខ្លួនស្គាល់ច្បាស់។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីស្តាប់ការសួរដេញដោលនាសវនាការឃើញថា បើទោះជាជនជាប់ចោទ បានឆ្លើយបដិសេធយ៉ាងណាក៏ដោយ តែជនរងគ្រោះបានបញ្ជាក់ថា គាត់ស្គាល់ជនជាប់ចោទច្បាស់ ហើយជនជាប់ចោទនេះបានវាយគាត់ទៀត, តំណាងមហាអយ្យការយល់ឃើញថា សំអាងហេតុនៃសាលក្រមដែលសាលាដំបូងលើកឡើង មានលក្ខណៈត្រឹមត្រូវ សុំសភាព្រហ្មទណ្ឌតម្កល់សាលក្រមរបស់សាលាដំបូងខេត្តកណ្តាលទុកជាបានការ។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

ខ្លួនជាមេធាវីការពារក្តីឲ្យឈ្មោះ [redacted] ប៊ុនធឿន ហៅ តុង ដែលត្រូវបានសាលាដំបូងខេត្តកណ្តាល សម្រេចផ្តន្ទាទោសតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ៣៩(ខ) ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដោយសម្រេចដាក់ទោសកូនក្តីខ្លួនដាក់ពន្ធនាគារកំណត់រយៈពេល ៦ឆ្នាំ ពីបទ ប្លន់ ប្រព្រឹត្តនៅភូមិត្រពាំងពើក ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៧ តាមមាត្រា៦ នៃច្បាប់ស្តីពីស្ពានទម្ងន់ទោសនៃបទឧក្រិដ្ឋ ហើយសាលក្រមនេះត្រូវបានកូនក្តីខ្លួនធ្វើការប្តឹងឧទ្ធរណ៍, មូលហេតុដែលកូនក្តីខ្លួនធ្វើការប្តឹងឧទ្ធរណ៍នោះ ដូចគាត់បានជម្រាបជូនក្នុងសវនាការសាលាឧទ្ធរណ៍នេះហើយថា គឺនៅចន្លោះឆ្នាំ២០០៧ គាត់មិនបានស្ថិតនៅទីក្រុងភ្នំពេញ ទេ គឺគាត់ទៅនៅជាមួយប្រពន្ធដើមរបស់គាត់ នៅខេត្តព្រៃវែង តែគាត់មានចម្លើយមួយទៀត ដែលបញ្ជាក់ថានៅក្នុងឆ្នាំ២០០៦ មិនមែនឆ្នាំ២០០៧ ទេ គាត់ធ្លាប់បានដឹកមនុស្ស២នាក់ ពីចោមចៅទៅថ្នល់ទទឹង ហើយគាត់ដឹកនៅវេលាម៉ោងប្រហែល៦ល្ងាច ហើយនៅពេលដែលគាត់ដាក់អ្នកដំណើរនោះចុះ គាត់បានទៅផឹកកាហ្វេមួយកែវ មួយសន្ទុះក្រោយមក ឃើញមានមនុស្ស២នាក់នោះមានការប្រទូស្តសារ៉ាយគ្នា នៅកន្លែងដែលមនុស្ស២នាក់នោះចុះ ហើយគាត់អត់បានធ្វើអ្វីទេ ក្រោយមកប្រហែលជា១០នាទី គាត់ក៏ត្រឡប់មកភ្នំពេញវិញ។ ដោយសារតែរឿងនេះ មិនមែនជាបទល្មើសជាក់ស្តែង ដោយហេតុថា អង្គហេតុនាំឲ្យមានការចោទប្រកាន់កូនក្តីខ្លួន គឺអង្គហេតុ កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៧ ហើយកូនក្តីខ្លួនត្រូវបានចាប់ខ្លួននៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដោយឡែកបើគិតពីកាលបរិច្ឆេទរយៈពេលឃុំខ្លួនគឺជាក់ស្តែង ខ្លួនមិនដឹងថាគាត់ជាប់ប៉ុន្មានករណីទេ ប៉ុន្តែបើគិតពីសាលក្រមនេះមានរយៈពេល៦ឆ្នាំ ដោយគិតពីថ្ងៃឃុំខ្លួន ថ្ងៃទី២២ ខែមករា ឆ្នាំ២០០៩, ចំណុចនេះសុំឲ្យលោកប្រធាន ក៏ដូចជាលោកចៅក្រមប្រឹក្សា មេត្តាពិចារណាផងដែរ ចំពោះចំណុចនេះ ហើយកូនក្តីខ្លួនបដិសេធរហូត បើទោះជាមានសាក្សីជាដើមបណ្តឹងគាត់បានបញ្ជាក់ថា គាត់បានឃើញកូនក្តីខ្លួនផ្ទាល់ ជាអ្នកវាយទៅលើគាត់ និងបក្សពួកទៀត ដូចនេះខ្លួនទុកសិទ្ធិជូនលោកចៅក្រមប្រធាន ក៏

ក៏ដូចជាលោកចៅក្រមប្រឹក្សា មេត្តាពិចារណាសម្រេចតាមច្បាប់។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ,

ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី,

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

<u>សាលាព្រហ្មទណ្ឌ</u>

<u>យល់ឃើញថាៈ</u>

១- បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ប៊ុនឈឿន ជាជនជាប់ចោទ ធ្វើក្នុងកំណត់ច្បាប់ តាមមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៧ នៅវេលាម៉ោងប្រមាណ២១យប់ មានករណីស្ទាក់ប្លន់ម៉ូតូមួយបានកើតឡើង ប្រព្រឹត្តដោយឈ្មោះ [redacted] ប៊ុនធឿន និងបក្សពួក បានជិះម៉ូតូស្ទាក់ពទ្ធ័ជនរងគ្រោះឈ្មោះ [redacted] រតនៈ និងនារី [redacted] ចាន់ណារី គំរាម និងប្លន់យកម៉ូតូជនរងគ្រោះ។

៣- ករណីនេះ ជនជាប់ចោទបានឆ្លើយនៅសវនាការនេះដំបូងថា នៅថ្ងៃកើតហេតុនោះ ខ្លួននៅដេកចិញ្ចឹមជ្រូកនៅខេត្តព្រៃវែងឯណោះ មិនបានមកភ្នំពេញទេ។ ក្រោយក្រុមប្រឹក្សាសាកសួរបញ្ជាក់ទើបឆ្លើយទទួលថា នៅពេលនោះខ្លួនបានដឹកមនុស្ស២នាក់ ពីចោមចៅទៅថ្កល់ទទឹងស្រុកអង្គស្នួល។ លុះទៅដល់ទីនោះ(កន្លែងកើតហេតុ) នៅវេលាម៉ោង៦ល្ងាច ខ្លួនទៅទិញបារីនៅក្បែរនោះ មួយសន្ទុះក្រោយមក ខ្លួនឃើញហេតុការណ៍កើតឡើងនៅកន្លែងដែលពីរនាក់នោះដើរចូលទៅ។ ខ្លួនជាអ្នករត់ម៉ូតូឌុប ខ្លួនពុំដឹងថាពីរនាក់នោះមានកាំភ្លើងទេ បើដឹងខ្លួនមិនឌុបគេទេ។

៤- តាមចម្លើយជនរងគ្រោះ នៅសវនាការនេះដែរថា នៅថ្ងៃកើតហេតុនោះ ខ្លួន និងគូដណ្តឹងបានជិះម៉ូតូទៅញ៉ាំបង្អែមនៅឯស្ពានគុណគ្រូ នៅវេលាម៉ោង១៧ និង៣០នាទី រួចត្រឡប់មកវិញដល់ផ្លូវបត់ចូលភូមិត្រពាំងពើក គូដណ្តឹងខ្លួនក៏បត់ចូលភូមិ ស្រាប់តែក្រុមជនជាប់ចោទមានគ្នា៣នាក់មកស្ទាក់ប្លន់យកម៉ូតូគូដណ្តឹងខ្លួនជិះទៅបាត់។ នៅពេលនោះជនជាប់ចោទរូបនេះហើយ ដែលជាអ្នកវាយខ្លួនបែកក្បាលហូរឈាម ខ្លួនស្គាល់ច្បាស់។

ដូច្នេះ ចម្លើយជនជាប់ចោទគ្រាន់តែជាចម្លើយដោះសារប៉ុណ្ណោះ មិនបានបញ្ជាក់ហេតុការណ៍ពិតឡើយ។

៥- មានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទពីបទ ប្លន់ ប្រព្រឹត្តនៅ ភូមិត្រពាំងពើក ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៧ បទល្មើសមានថ្ងៃ និងឲ្យផ្តន្ទា...

ទោសតាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

៦- សាលក្រមព្រហ្មទណ្ឌលេខ ៣៩ (ខ) ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តកណ្តាល សម្រេចមានលក្ខណៈត្រឹមត្រូវ គួរតម្កល់ទុកជាបានការ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១- ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ប៊ុនឈឿន ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៩ (ខ) ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តកណ្តាល ទុកជាបានការពេញទាំងមូល។

៣- បង្គាប់ឲ្យបន្តឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៤ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវសាទុក្ខ០១ខែ គិតចាប់ពីថ្ងៃប្រកាសសាលដីកានេះទៅ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០១៥
ក្រឡាបញ្ជី
[redacted]